-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសារាចរលេខ ០៤ សរ ចុះថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល

-តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១ .- ត្រូវបានដាក់អោយលោក ពេជ្រ គឹមស្រ៊ាង នាយករាជអយស្ម័យយានកម្ពុជា ចូលនិវត្តន៍ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៩ តទៅ ។

មាត្រា ២ .-តែងតាំង លោក សុខុម គគទន្តមុនី នាយករងរាជអយស្ម័យយានកម្ពុជា ជានាយករាជអយស្ម័យយានកម្ពុជា ជំនួសលោក ពេជ្រ គឹមស្រ៊ាង ដែលត្រូវចូលនិវត្តន៍ ។

មាត្រា ៣ .- រាល់បទបញ្ញត្តិ ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងអស់លោក ដែលមានរាយនាមក្នុងមាត្រា១ និង មាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## ២-សេចក្តីសម្រេច

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៩

### សេចក្តីសម្រេច លេខ ៦៦ សសរ

### ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យជនបរទេស

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការត្រួតពិនិត្យ ជនបរទេសនៅតាម រោងចក្រ ក្លឹបកំសាន្ត សណ្ឋាគារ ផ្ទះសំណាក់ អោជនីយដ្ឋាន ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១-ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា | ប្រធាន |
| ២-ឯកឧត្តម ឡុង វិសាលោ | អនុរដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម ហ៊ុល លឹម | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ៤-ឯកឧត្តម តេង សាវង្ស | អគ្គនាយករងនគរបាលជាតិ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឯកឧត្តម គ្រាញ់ តូនី | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៦-ឯកឧត្តម ម៉ប់ សារិន | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ៧-ឯកឧត្តម ឃឹម មូ | អភិបាលរងទី១ ខេត្តកណ្តាល | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

-ចុះត្រួតពិនិត្យជាក់ស្តែង និងធ្វើស្ថិតិជនបរទេសទាំងអស់ ដែលបាន និងកំពុងរស់នៅធ្វើការងារនៅតាមបណ្តារោងចក្រ ក្លឹបកំសាន្ត សណ្ឋាគារ ផ្ទះសំណាក់ អោជនីយដ្ឋាននានានៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ។

-ក្នុងករណីពិនិត្យឃើញជនបរទេសទាំងឡាយណាដែលបាន និងកំពុងស្នាក់នៅមិនស្របច្បាប់ ត្រូវលើកវិធានការដោះស្រាយជូនរាជរដ្ឋាភិបាលសំរេច ។

-ធ្វើរបាយការណ៍រៀងរាល់សប្តាហ៍-អំពីលទ្ធផលការងាររបស់ខ្លួនជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន គណៈកម្មការ ។

**ប្រការ ៤ :** គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារ ដើម្បីជួយការងារ ប្រសិនបើចាំបាច់ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពល ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរងទី១ រាជធានីភ្នំពេញ ឯកឧត្តមអភិបាលខេត្តកណ្តាល និង ឯកឧត្តមដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

★★★

## ៣-សារាចរ

ភ្នំពេញ, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៩

## សារាចរលេខ ១៥ សរណន

### ស្តីពី

### ការធ្វើជំរឿនមន្ត្រីរាជការ និង វិភាគមុខងារ

* * *

ក្នុងការអនុវត្តកម្មវិធីកែទំរង់រដ្ឋ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចអោយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលនូវបេសកកម្មកែលំអរដ្ឋបាលសាធារណៈ បច្ចុប្បន្នអោយក្លាយទៅជារដ្ឋបាលមួយមានលក្ខណៈកាន់តែប្រតិបត្តិការប្រកបដោយផលិតភាព គុណនេយ្យភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងការបំពេញមុខងារបំរើសេវាសាធារណៈ ។

ដើម្បីសំរេចបាននូវគោលដៅទាំងនេះ រាជរដ្ឋាភិបាលតំរូវអោយគ្រប់ក្រសួង ស្ថាប័ននានា គ្រប់ខេត្ត-ក្រុងទាំងអស់ចូលរួមសហការ និងរៀបចំធ្វើជំរឿនមន្ត្រីរាជការ និងវិភាគមុខងារ ទៅតាមបេសកកម្មទាំងឡាយ ដែលមានកំណត់ក្នុងលិខិតបទដ្ឋានអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ននីមួយៗអោយបានច្បាស់លាស់តាមវិធីសាស្ត្រ ដូចខាងក្រោម :

I-ការធ្វើជំរឿនមន្ត្រីរាជការ :

១-គោលបំណងនៃការធ្វើជំរឿន :

ការធ្វើជំរឿនរូបវន្តមន្ត្រីរាជការ មានគោលបំណងសំខាន់ៗគឺ

- ក្តាប់អោយបានច្បាស់នូវអត្តសញ្ញាណ នៃមន្ត្រីរាជការម្នាក់ៗពាក់ព័ន្ធនឹងស្ថានភាពរដ្ឋបាល ស្ថានភាពការងារ ស្ថានភាពគ្រួសារ ការបណ្តុះបណ្តាល និង បទពិសោធក្នុងមុខងារវិជ្ជាជីវៈ
- ចងក្រងសំណុំលិខិតផ្ទាល់ខ្លួនរបស់មន្ត្រីរាជការម្នាក់ៗ
- រកអោយឃើញនូវចំនួនមន្ត្រីខ្មោច និងមន្ត្រីអនិយ័ត ដើម្បីមានវិធានការលុបឈ្មោះចេញពីក្របខ័ណ្ឌរដ្ឋ
- រៀបចំ និងពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ អោយមានប្រសិទ្ធភាព តាមនីតិវិធីរដ្ឋបាល